ក្រុមសៀវភៅការរុករកឃើញ®



# តើអ្នក ព្រួយបារម្ភពីអ្វី?

What are you worried about?



ការស្វែងយល់ស៊ីជម្រៅ




# តើអ្នកព្រួយបារម្ភពីអ្វី?

**មនុស្សជាច្រើនគេងមិនលក់** ដោយការព្រួយបារម្ភអំពីសមាជិកគ្រួសារ បញ្ហាសុខភាព រឿងលុយកាក់ ឬបញ្ហារាប់ពាន់ជំពូកទៀត។ ការព្រួយបារម្ភអាចបង្ហាញខ្លួនចេញមកឲ្យគេដឹង តាមរបៀបខុសៗគ្នា។ វាស៊ីបំផ្លាញគំនិតរបស់យើង វាធ្វើឲ្យយើងមានអារម្មណ៍មិនមូល ហើយអាចធ្វើឲ្យយើងឈឺក្បាល ឬកើតជម្ងឺស្រឹត។ អ្នកខ្លះបានព្យាយាមលាក់បាំងការព្រួយបារម្ភ ដោយព្យាយាមធ្វើឲ្យខ្លួនឯងគិត ឬជាប់រវល់នឹងរឿងអ្វីផ្សេង។ ទោះយើងជានរណាក៏ដោយ ការព្រួយបារម្ភ គឺជាបញ្ហាដែលយើងត្រូវប្រឈមមុខដោះស្រាយ។

តើការព្រួយបារម្ភ សុទ្ធតែអាក្រក់ឬ? ការខ្វល់ខ្វាយអាចបង្ហាញថាយើងកំពុងតែមានការទទួលខុសត្រូវ និងយកចិត្តទុកដាក់ចំពោះរឿងដែលកំពុងកើតឡើង ចំពោះយើង និងអ្នកដែលយើងស្រឡាញ់។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាស្ថិតនៅត្រង់ថា តើយើងមានដំណោះស្រាយយ៉ាងណាសម្រាប់ការព្រួយបារម្ភរបស់យើង?

តើយើងល្វើយ និងចុះខ្សោយកម្លាំង ដោយសារការថប់បារម្ភរបស់យើង ដោយមិនមានដំណោះស្រាយឬ? មានកាលៈទេសៈ និងបញ្ហាប្រឈមជា

ច្រើន ដែលយើងមិនអាចគ្រប់គ្រងបានទាល់តែសោះ។ ជួនកាល យើងប្រឈមមុខនឹងការសម្រេចចិត្ត ដែលពិបាកបំផុត ហើយយើងចេះតែមានការភ័យខ្លាច ចំពោះពេលអនាគត ហើយហេតុការណ៍ ឬកំហុសពីអតីតកាល អាចបន្តតាមលងយើង ហើយធ្វើឲ្យយើងពេញដោយការថប់បារម្ភ។

តើការព្រួយបារម្ភរបស់យើងបាននាំយើងឲ្យងាកទៅពឹងផ្អែកលើព្រះជាម្ចាស់ ដែលយកព្រះទ័យទុកដាក់ចំពោះយើងឬទេ(១ពេត្រុស ៥:៧)? ព្រះគម្ពីរបានចែងថា គ្មានរឿងអ្វីដែលព្រះជាម្ចាស់មិនអាចដោះស្រាយបាន ហើយក៏គ្មានបញ្ហាអ្វីដែលពិបាកពេកសម្រាប់ទ្រង់ ឬអាចឈ្នះទ្រង់នោះឡើយ។ ដូចនេះ តើព្រះអម្ចាស់អាចជួយឲ្យយើងឈ្នះការព្រួយបារម្ភរបស់យើង ដោយរបៀបណា?

---

*"បញ្ហាស្ថិតនៅត្រង់ថា តើយើងមានដំណោះស្រាយយ៉ាងណា សម្រាប់ការព្រួយបារម្ភរបស់យើង?*

---

# ការចាកចេញមករកព្រះ

**ព្រះទ្រង់មិនដែលសព្វព្រះទ័យ**ឲ្យយើងដោះស្រាយ ឬគ្រប់គ្រងបញ្ហា ឬការព្រួយបារម្ភរបស់យើងតែម្នាក់ឯងនោះទេ។ ទ្រង់បានបង្កើតយើងមក សម្រាប់ឲ្យរស់នៅជាមួយទ្រង់ ក្នុងទំនាក់ទំនងដែលមានសុវត្ថិភាព និងមានក្ដីស្រឡាញ់។ ព្រះយេស៊ូវជាព្រះពិតតែមួយ ដែលបានយាងចុះមកផែនដីកាលពី២០០០ឆ្នាំមុន ដើម្បីសុគតនៅលើឈើឆ្កាង។ ទ្រង់បានសុគត ដោយទទួលទោសជំនួសយើង គឺទោសដែលយើងសមនឹងទទួល ដោយសារអំពើបាបរបស់យើង ដែលក្នុងនោះ យើងបានបដិសេធ និងធ្វើព្រងើយចំពោះទ្រង់។ បីថ្ងៃក្រោយមក ទ្រង់ក៏បានមានព្រះជន្មរស់ឡើងវិញ។

នេះជាជីវិតថ្មី ដែលទ្រង់បានប្រទាន សម្រាប់ឲ្យយើងរស់នៅជាមួយទ្រង់។ គ្រីស្ទបរិស័ទគឺជាអ្នកដែលជឿទុកចិត្តថា ព្រះយេស៊ូវនឹងនាំពួកគេចូលទៅក្នុងទំនាក់ទំនងថ្មីមួយ ជាមួយទ្រង់។ បានសេចក្ដីថា ពួកគេជាកម្មសិទ្ធិរបស់ទ្រង់ហើយ ដូចនេះ ការព្រួយបារម្ភ និងការខ្វល់ខ្វាយរបស់ពួកគេ ក៏ជារបស់ទ្រង់ផងដែរ។

ពេលដែលយើងមានការព្រួយបារម្ភ តាមធម្មតា យើងផ្ដោតទៅលើលទ្ធភាពដែលអាចដោះស្រាយបាន ដែលមិនទាន់មាន ឬលើសពីសមត្ថភាពដែលយើងអាចគ្រប់គ្រងបាន។ ប៉ុន្តែ អស់អ្នកដែលទុកចិត្តព្រះយេស៊ូវ អាចសម្រេចចិត្តផ្ដោតទៅលើទ្រង់ ជាជាងផ្ដោតទៅលើបញ្ហាដ៏តានតឹងនោះ។

ពេលដែលយើងព្រួយបារម្ភ គឺមានន័យថា យើងកំពុងតែទទួលស្គាល់

ការពិតដែលថា យើងមិនអាចដោះស្រាយបញ្ហាទាំងអស់ ដោយពឹងកម្លាំងខ្លួនឯងបាន។ ពេលដែលយើងមានការព្រួយបារម្ភ គឺជាពេលដែលយើងត្រូវនឹកចាំថា ព្រះទ្រង់ជានរណា ទ្រង់មានចរិយាសម្បត្តិ ព្រះបន្ទូលសន្យា និងអំណាចអ្វីខ្លះ។

គ្មានការអ្វីដែលបានកើតឡើងក្នុងពិភពលោកនេះ ដោយទ្រង់មិនបានជ្រាបនោះទេ។ ព្រះគម្ពីរបានប្រាប់យើងថា ព្រះអម្ចាស់បានតាំងបល្ល័ង្កទ្រង់នៅលើស្ថានសួគ៌ ហើយរាជ្យទ្រង់ក៏គ្រប់គ្រងលើទាំងអស់(ទំនុកដំកើង ១០៣:១៩)។ មានតែព្រះជាម្ចាស់ទេ ដែលពិតជាបាន និងកំពុងតែគ្រប់គ្រងពិភពលោក ហើយយើងអាចនាំការព្រួយបារម្ភ និងការភ័យខ្លាចរបស់យើង ថ្វាយដល់ទ្រង់។ មានការសំខាន់មួយចំនួន ដែលយើងត្រូវចាំក្នុងអំឡុងពេលដែលយើងមានភាពតានតឹង។

**ទីមួយ យើងត្រូវចាំថា ទ្រង់គង់នៅគ្រប់ទីកន្លែង។** គ្មានទីកន្លែងណាដែលទ្រង់មិនអាចទៅដល់នោះទេ ទោះយើងមានអារម្មណ៍ថាឯកោយ៉ាងណាក៏ដោយ។ និយាយរួម ទ្រង់គង់នៅគ្រប់ទីកន្លែង(ទំនុកដំកើង ១៣៩:៧-១២)។

**ទីពីរ យើងត្រូវចាំថា ទ្រង់ជ្រាបអំពីអ្វីៗទាំងអស់។** ទ្រង់ជ្រាបថា មានរឿងអ្វីដែលធ្វើឲ្យយើងព្រួយបារម្ភ ហើយមានរឿងអ្វីដែលធ្វើឲ្យយើងភ័យខ្លាច។ ព្រះទ្រង់ជ្រាប និងចូលទៅក្នុងស្ថានភាពរបស់យើងទាំងស្រុង។ ព្រះទ្រង់ស្គាល់ ហើយអាចបំពេញតម្រូវការដែលជ្រាលជ្រៅបំផុតរបស់យើង(ទំនុកដំកើង ៣៣:១៣-១៤)។

**ទីបី យើងត្រូវចាំថា ទ្រង់មានគ្រប់អំណាចចេស្តា។** ព្រះទ្រង់មានអំណាចដែលគ្មានដែនកំណត់ ដែលអាចជួយយើងបាន។ ហើយយើងអាចទុកចិត្តថា ទ្រង់បំពេញតម្រូវការរបស់យើង តាមពេលវេលាដែលទ្រង់

បានរៀបចំយ៉ាងល្អឥតខ្ចោះ។ ទ្រង់ជ្រាបអំពីរបស់ល្អបំផុត ដែលយើងគួរទទួល ទោះវាមិនមែនជាអ្វីដែលយើងរំពឹងចង់បានក៏ដោយ(ម៉ាថាយ ១៩:២៦)។

**ទ្រង់យកព្រះទ័យទុកដាក់ចំពោះយើង។** ដោយសារព្រះយេស៊ូវបានសុគត ជំនួសយើងនៅលើឈើឆ្កាង យើងអាចដឹងច្បាស់ថា ទ្រង់ស្រឡាញ់យើង ហើយគ្មានអ្វីអាចពង្រាត់យើង ចេញពីក្តីស្រឡាញ់របស់ព្រះអង្គបានឡើយ(រ៉ូម ៨:៣៨-៣៩)។ យើងអាចថ្វាយការព្រួយបារម្ភទាំងអស់ នៅលើស្មាទ្រង់។ ទ្រង់ថែមទាំងយកព្រះទ័យទុកដាក់ចំពោះសុខភាព ការងារ មិត្តភក្តិ និងគ្រួសាររបស់យើង ច្រើនជាងយើងខ្វល់អំពីពួកគេទៀតផង។

**យើងក៏ត្រូវចាំផងដែរថា ទ្រង់មិនដែលចាកចេញពីយើង។** កាលណាយើងមានការព្រួយបារម្ភកាន់តែខ្លាំងប៉ុណ្ណា យើងក៏កាន់តែមានអារម្មណ៍ឯកោ និងអស់សង្ឃឹម។ ប៉ុន្តែ បើយើងជាកម្មសិទ្ធិរបស់ព្រះ នោះយើងមិនចាំបាច់ត្រូវសែងបន្ទុកគ្រប់យ៉ាង ដោយខ្លួនឯងទៀតឡើយ។ ក្នុងបទគម្ពីរទំនុកដំកើង ជំពូក១៣៩ ស្តេចដាវីឌ (ដែលជាទាហាន និងជាស្តេច) បានសរសេរអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់ ដែលគង់ជាមួយយើងជាប់ជានិច្ច។ ស្តេចដាវីឌមានបន្ទូលថា ព្រះជាម្ចាស់ស្គាល់ទ្រង់គ្មានកន្លែងចន្លោះ តាំងពីមុនទ្រង់ចាប់កំណើត(ខ.១៣-១៦)។ តាមពិត យើងមិនអាចគេចចេញពីព្រះវត្តមានព្រះ ទោះយើងទៅកន្លែងណាក៏ដោយ(ខ.៧-១២)។ ទោះនៅពេលព្រឹក ឬយប់ នៅលើដីគោក ឬនៅក្នុងសមុទ្រ នៅកន្លែងខ្ពស់យ៉ាងណា ឬក្នុងកន្លែងជ្រៅយ៉ាងណា ព្រះទ្រង់ក៏គង់នៅទីនោះផងដែរ។

# ប៉ុន្តែ តើយើងថ្វាយការព្រួយបារម្ភរបស់យើង ដល់ព្រះជាម្ចាស់ដោយរបៀបណា?

ចម្លើយនោះគឺ : **យើងថ្វាយការព្រួយបារម្ភរបស់យើង** ដល់ទ្រង់ មិនមែនតាមរយៈការអ្វីដែល យើងធ្វើនោះទេ តែតាមរយៈអ្វីដែលយើងជឿ។ តើយើងកំពុងតែជឿលើអារម្មណ៍ និងសមត្ថភាពខ្លួនឯងឬ? ឬមួយយើងទុកចិត្តព្រះបន្ទូល និងសេចក្តីសន្យាក្នុងព្រះគម្ពីរ ដែលថា ព្រះជាម្ចាស់មានអំណាចចេស្តា និងគួរឲ្យយើងទុកចិត្ត?

ស្តេចដាវីឌបានជ្រាបអំពីអត្ថន័យនៃការទុកចិត្តព្រះ ក្នុងអំឡុងពេលដែលទ្រង់អស់សង្ឃឹម។ ទ្រង់បានសរសេរអំពីសង្គ្រាម ភាពក្រីក្រ និងអំពីមនុស្សដែលបានព្យាយាមយ៉ាងសកម្ម ដើម្បីធ្វើគុតទ្រង់ ។ នៅពេលនោះទ្រង់បានមានបន្ទូលថា អ្នកដែលទុកចិត្តព្រះ និងមានចិត្តស្ងប់ស្ងល់(ទំនុកដំកើង ៣៧:១៩)។ បានសេចក្តីថា អ្នកដែលទុកចិត្តព្រះ នឹងបានទទួលលទ្ធផល ដូចដែលខ្លួនរំពឹងចង់បាន តាមបំណងព្រះទ័យទ្រង់។ ពេលដែលយើងមានការព្រួយបារម្ភ យើងមិនចាំបាច់ត្រូវភ័យខ្លាចឡើយ។ ព្រះជាម្ចាស់នឹងគង់នៅជាមួយយើង និងផ្គត់ផ្គង់យើង។

*"ព្រះជាម្ចាស់នឹងគង់នៅជាមួយយើង និងផ្គត់ផ្គង់យើង"។*

ការនេះមិនបានសន្យាថា ការអាក្រក់នឹងមិនកើតឡើងចំពោះយើងនោះឡើយ។ យើងគ្រប់គ្នានឹងឆ្លងកាត់ពេលដ៏ពិបាក ហើយព្រួយបារម្ភអំពីរឿងជាច្រើន។ ប៉ុន្តែ ព្រះគម្ពីរបានសន្យាថា យើងអាចទុកចិត្តព្រះជាម្ចាស់។ យើងថ្វាយការព្រួយបារម្ភរបស់យើងដល់ទ្រង់ ពេលដែលយើងសម្រេចចិត្ត

ថា យើងទុកចិត្ត និងពឹងផ្អែកលើទ្រង់ ជាជាងទុកចិត្ត និងពឹងផ្អែកខ្លួនឯង ឬនរណាម្នាក់។

ព្រះយេស៊ូវបានពន្យល់ថា ការថ្វាយការព្រួយបារម្ភរបស់យើងដល់ព្រះ គឺជាអទិភាពរបស់យើង។ យើងងាយនឹងព្រួយបារម្ភអំពីអាហារ សម្លៀកបំពាក់ និងអនាគតរបស់យើង ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលថា "ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"(ម៉ាថាយ ៦:៣៣)។ ព្រះយេស៊ូវមានបន្ទូលថា អ្វីដែលយើងត្រូវខ្វល់មុនគេ គឺត្រូវស្គាល់ព្រះ ដោយផ្លាស់ប្រែឲ្យមានលក្ខណៈដូចទ្រង់(ដែលជា "ភាពសុចរិត") ហើយរស់នៅថ្វាយទ្រង់។ នេះគឺជាអទិភាពរបស់យើង។ ពេលដែលយើងបានដាក់អាទិភាពយ៉ាងដូចនេះ ហើយចំណាយពេលជាមួយព្រះ នោះយើងនឹងកាន់តែមានទំនុកចិត្តថា អ្វីៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។

ព្រះជាម្ចាស់បានបង្កើតយើងមកឲ្យពឹងផ្អែកលើទ្រង់ ដោយត្រាប់តាមចរិយាសម្បត្តិ និងសេចក្ដីស្រឡាញ់របស់ទ្រង់។ ពេលណាយើងបន្តព្រួយបារម្ភ អំពីបញ្ហាក្នុងជីវិតយើង នោះមានន័យថា យើងកំពុងតែធ្វើឲ្យខ្លួនឯងនៅឆ្ងាយពីទ្រង់កាន់តែខ្លាំង។

---

*"ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"(ម៉ាថាយ ៦:៣៣)។*

---



## ការកែប្រែការព្រួយបារម្ភ ឲ្យក្លាយជាទៅជាការអធិស្ឋាន

**មានមនុស្សមិនច្រើនទេ ដែលបានឆ្លងកាត់បញ្ហា** ដែលសាវ័កប៉ុលបានជួប។ ក្នុងនាមគាត់ ជាសាវ័ករបស់ព្រះយេស៊ូវ ដែលបាននិពន្ធកណ្ឌគម្ពីរជាច្រើន ក្នុងព្រះគម្ពីរសញ្ញាថ្មី គាត់បានចំណាយជីវិតរបស់គាត់ជាគ្រីស្ទបរិស័ទ ដើម្បីប្រាប់គេ អំពីព្រះយេស៊ូវ និងអំពីជីវិតថ្មីដែលព្រះជាម្ចាស់បានប្រទាន។ ត្រង់ចំណុចនេះ សាវ័កប៉ុលក៏មានសត្រូវជាច្រើន ក្នុងចំណោមជនរួមជាតិរបស់គាត់ ដែលបានចាត់ទុកជំនឿលើព្រះគ្រីស្ទ ជាការគំរាមកំហែងទៅដល់សន្តិសុខជាតិរបស់ពួកគេ។

ប៉ុន្តែ ទោះជាគេបានគំរាមកំហែងគាត់ វាយដំ និងដាក់គុកគាត់ក៏ដោយ ក៏គាត់នៅតែសរសេរក្នុងសំបុត្ររបស់គាត់ថា "កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នា ក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង"(ភីលីព ៤:៦-៧)។

---

*"ការអធិស្ឋានជួយលើកយើង ចេញពីបញ្ហារបស់យើង ដើម្បីឲ្យយើងមើលឃើញពិភពលោកតាមទស្សនៈរបស់ព្រះ។*

---

នៅក្នុងការបង្រៀនរបស់សាវ័កប៉ុល អំពីរបៀបគ្រប់គ្រងការព្រួយបារម្ភ គាត់បានប្រើពាក្យគន្លឹះបី។

**ការអធិស្ឋាន** : ការអធិស្ឋាន គឺជាការសន្ទនាជាមួយព្រះ។ វាជាពេលដែលយើងសម្រេចចិត្តផ្តោតទៅលើព្រះចរិយាសម្បត្តិ និងព្រះបន្ទូលសន្យារបស់ទ្រង់ នៅក្នុងថ្ងៃនីមួយៗ។ ការ

អធិស្ឋានគឺជាការនិយាយទៅកាន់ព្រះថា ទ្រង់ជានរណា ហើយទ្រង់បានធ្វើឲ្យយើងក្លាយជានរណា។ ការអធិស្ឋានជាការឆ្លើយតប ចំពោះអ្វីដែលយើងបានអានអំពីទ្រង់ ក្នុងព្រះគម្ពីរ ហើយជួយយើងឲ្យជញ្ជឹងគិតថា ទ្រង់អស្ចារ្យ មានអំណាចចេស្តា មានក្តីស្រឡាញ់ និងគួរឲ្យស្ញែងខ្លាចប៉ុណ្ណា។ ការអធិស្ឋានជួយលើកយើង ចេញពីបញ្ហារបស់យើង ដើម្បីឲ្យយើងមើលឃើញពិភពលោក តាមទស្សនៈរបស់ព្រះ។

**ការទូលអង្វរ :** ពេលណាយើងគិតអំពីភាពធំប្រសើររបស់ព្រះ និងសេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះយើង យើងអាចទុកចិត្តទ្រង់ និងទូលសូមទ្រង់ជួយយើងជម្នះការព្រួយបារម្ភ និងទុក្ខលំបាករបស់យើង។ ទ្រង់អាចជួយដោះស្រាយ ហើយដឹកនាំយើងឆ្លងកាត់បញ្ហាទាំងនោះ។

**ការអរព្រះគុណ :** ការអរព្រះគុណហាក់ដូចជា ទង្វើរដ៏ចម្លែកសម្រាប់អ្នកដែលកំពុងតែព្រួយបារម្ភ។ ប៉ុន្តែ ការអរព្រះគុណ គឺជាការឆ្លើយតបដ៏ត្រឹមត្រូវ និងមានអំណាច ចំពោះការថប់បារម្ភ។ គ្រីស្ទបរិស័ទមានហេតុផលច្រើនណាស់ ដែលត្រូវអរព្រះគុណព្រះ ព្រោះពួកគេបានទទួលការសង្គ្រោះពីព្រះយេស៊ូវ ហើយទ្រង់បាននាំពួកគេត្រឡប់មករកព្រះជាម្ចាស់វិញ និងបានសន្យាថានឹងរៀបចំកន្លែងនៅនគរស្ថានសួគ៌ សម្រាប់ពួកគេ( យ៉ូហាន ១៤:១-៦ )។ ពេលណាយើងនាំការព្រួយបារម្ភរបស់យើង ថ្វាយដល់ព្រះ ដោយការអរព្រះគុណ គឺមិនមានន័យថា យើងអរព្រះគុណព្រះអង្គ សម្រាប់ទុក្ខលំបាករបស់យើងនោះឡើយ។ តែវាមានន័យថា យើងអរព្រះគុណ ព្រោះយើងដឹងថា ព្រះអង្គបានធ្វើអ្វីខ្លះសម្រាប់យើង

---

*"គ្រីស្ទបរិស័ទមានហេតុផលច្រើនណាស់ ដែលត្រូវអរព្រះគុណព្រះ ព្រោះពួកគេបានទទួលការសង្គ្រោះពីព្រះយេស៊ូវ"។*

---

កាលពីមុន ហើយយើងដឹងថា ទ្រង់កំពុងតែធ្វើការសម្រាប់យើង ក្នុងពេលបច្ចុប្បន្ន ទោះយើងប្រហែលជាមិនបានមើលឃើញទ្រង់ធ្វើការ ភ្លាមៗក៏ដោយ។ យើងអាចអរព្រះគុណព្រះអង្គ សម្រាប់ការស្រឡាញ់យើង និងយល់អំពីទុក្ខលំបាករបស់យើង ហើយបានសន្យាថា នឹងផ្គត់ផ្គង់យើង។

តើយើងនឹងទទួលលទ្ធផលយ៉ាងដូចម្តេច ពីការអធិស្ឋាន? តើការអធិស្ឋានរបស់យើង នឹងដោះស្រាយបញ្ហា រហ័សដូចផ្លេកបន្ទោរឬ? ទេ។ ពេលដែលយើងថ្វាយការព្រួយបារម្ភរបស់យើងដល់ព្រះ ទ្រង់នឹងឆ្លើយតបតាមពេលវេលារបស់ទ្រង់ ទោះការឆ្លើយតបនោះ មិនឆាប់រហ័សដូចការរំពឹងគិតរបស់យើងក៏ដោយ។ ប៉ុន្តែ ពេលយើងអធិស្ឋាន យើងអាចពិសោធន៍នឹង "សេចក្តីសុខសាន្ត ឬសន្តិភាពរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត"។ សន្តិភាពរបស់ទ្រង់លើសពីការយល់ដឹងរបស់យើង ព្រោះកាលៈទេសៈរបស់យើង មិនទាន់មានការផ្លាស់ប្តូរភ្លាមៗនោះទេ។ បញ្ហាយើងនៅមានដដែល ប៉ុន្តែ សាវ័កប៉ុលបានមានប្រសាសន៍ថា យើងនឹងបានពិសោធន៍នឹងសន្តិភាព ឬសេចក្តីសុខសាន្តរបស់ទ្រង់។ សេចក្តីសុខសាន្តនេះ គឺផ្អែកទៅលើជំនឿដែលយើងមានចំពោះព្រះជាម្ចាស់ គឺមិនមែនដោយសារបញ្ហាយើងរលាយបាត់ភ្លាមៗនោះឡើយ។

---

*ពេលដែលយើងថ្វាយការព្រួយបារម្ភរបស់យើងដល់ព្រះ ទ្រង់នឹងឆ្លើយតប តាមពេលវេលារបស់ទ្រង់*

---



# ការកែប្រែការព្រួយបារម្ភឲ្យក្លាយជាឱកាស

**ការព្រួយបារម្ភអាចនាំយើងចូលទៅជិតព្រះ** រហើយក៏អាចនាំយើងចេញឆ្ងាយពីទ្រង់ផងដែរ។ ថ្នាំព្យាបាល សម្រាប់ការព្រួយបារម្ភ គឺមិនមែនជាភាពឯករាជ(ការពឹងខ្លួនឯង)នោះឡើយ ប៉ុន្តែ ជាការពឹងផ្អែកលើព្រះជាម្ចាស់។

ពេលណាអ្នកដើរតាមព្រះយេស៊ូវមានការព្រួយបារម្ភ តើពួកគេព្រួយបារម្ភអំពីអ្វី ហើយតើពួកគេធ្វើអ្វី ដើម្បីជម្នះការព្រួយបារម្ភ? គ្រីស្ទបរិស័ទមានការព្រួយបារម្ភដូចមនុស្សទូទៅ ប៉ុន្តែ កាលណាពួកគេបានស្គាល់ព្រះកាន់តែច្បាស់ ពួកគេដឹងថា ពួកគេអាចថ្វាយការព្រួយបារម្ភរបស់ពួកគេដល់ទ្រង់ ដោយទុកចិត្តទ្រង់។ បើសិនជាព្រះជាម្ចាស់បានទទួលដោះស្រាយបញ្ហារបស់ពួកគេហើយ នោះមានន័យថា ទ្រង់បានរំដោះពួកគេឲ្យរួចពីការព្រួយបារម្ភនោះ ដើម្បីឲ្យពួកគេអាចផ្តោតទៅលើការអ្វី ដែលទ្រង់សព្វព្រះទ័យឲ្យពួកគេខ្វល់។ តើទ្រង់សព្វព្រះទ័យឲ្យយើងខ្វល់ពីអ្វី? គឺខ្វល់អំពីការនាំមនុស្សកាន់តែច្រើនឲ្យទទួលជឿព្រះយេស៊ូវ ហើយផ្សះផ្សាទំនាក់ទំនងជាមួយទ្រង់ឡើងវិញ។

ហើយយើងក៏គួរតែខ្វល់អំពីរឿងនេះជាទីមួយ ផងដែរ។ ប៉ុន្តែ យើងមិនអាចខ្វល់ពីរឿងនេះបានទេ បើសិនជាយើងកំពុងតែត្រូវបានរំខានដោយការព្រួយបារម្ភផ្ទាល់ខ្លួនជាទីមួយហើយនោះ។ ការនេះមិនមានន័យថា ក្តីកង្វល់ដែលយើងមានជាប្រចាំថ្ងៃ សុទ្ធតែជារឿងមិនត្រឹមត្រូវ ឬមិនសំខាន់នោះឡើយ។ មានរឿងជាច្រើនដែលសំខាន់ ហើយព្រះទ្រង់ក៏ជ្រាបផងដែរ។ ប៉ុន្តែ ព្រះជាម្ចាស់អាចជួយយើងបានច្រើនជាងយើងជួយខ្លួនឯង។

បើយើងអាចចាប់ផ្តើមថ្វាយការព្រួយបារម្ភដល់ទ្រង់ យើងនឹងបានដឹងថា យើងអាចពឹងផ្អែកលើទ្រង់បានច្រើនប៉ុណ្ណា។ ហើយពេលដែលយើងមានទំនុកចិត្តកាន់តែច្រើន ដោយដឹងថា ជីវិតយើងកំពុងតែនៅក្នុងព្រះហស្តទ្រង់ យើងនឹងអាចចែករំលែកទំនុកចិត្តយើង ជាមួយអ្នកដទៃ។ កាលណាយើងយកចិត្តទុកដាក់ចំពោះអ្នកដទៃ ហើយជួយពួកគេ គឺមានន័យថា យើងបានចូលរួមជាមួយទ្រង់ នៅក្នុងការខ្វល់អំពីមនុស្សជាច្រើន ដែលមិនទាន់ស្គាល់ទ្រង់។

# ទីបន្ទាល់អំពីការព្រួយបារម្ភ

នេះ **ទីបន្ទាល់របស់**មនុស្សម្នាក់ ដែលបានតយុទ្ធនឹងខ្វល់ព្រួយ និងការថប់បារម្ភ។ គាត់ប្រាប់យើងថា ពេលដែលគាត់ផ្តោតទៅលើព្រះជាម្ចាស់ គាត់ក៏បានរកឃើញវិធីសាស្ត្រល្អជាងមុន ដើម្បីជម្នះភាពតានតឹងរបស់គាត់។ គាត់ថា ព្រះជាម្ចាស់បានជំរុញចិត្តគាត់ ឲ្យជម្នះការព្រួយបារម្ភរបស់គាត់ តាមបទគម្ពីរ ភីលីព ១:៦ ដែលបានចែងថា "ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ"។ ប៉ុន្តែ មិនយូរប៉ុន្មាន ខ្ញុំក៏បានដឹងថា ដំណើរការនៃការផ្លាស់ប្រែឲ្យមានលក្ខណៈដូចព្រះយេស៊ូវ មិនបានឆ្លងកាត់ការរៀនសូត្រ៦មេរៀនងាយៗ ឬអស់ពេល៦ខែនោះឡើយ ប៉ុន្តែ ត្រូវបន្តរហូតដល់ពេលដែលយើងបានទៅរស់នៅនគរស្ថានសួគ៌ជាមួយទ្រង់។

ព្រះជាម្ចាស់បានបង្ហាញឲ្យគាត់ស្គាល់ការលត់ដំបួនយ៉ាង ដែលមានឥទ្ធិពលយ៉ាងខ្លាំង មកលើជីវិតគាត់ ដែលមានដូចជា ការអានព្រះបន្ទូល ការអធិស្ឋាន ការទុកចិត្ត និងការស្តាប់បង្គាប់។ យើងត្រូវអានព្រះគម្ពីរ។ យើងត្រូវជជែក(អធិស្ឋាន) ជាមួយព្រះ (អានមានរយៈពេលវែង ឬខ្លី)។ យើងក៏ត្រូវទុកចិត្តព្រះ ចំពោះការអ្វីដែលយើងមិនអាចគ្រប់គ្រងបាន។ ហើយយើងស្តាប់បង្គាប់ទ្រង់ ក្នុងរឿងអ្វីដែលយើងអាចគ្រប់គ្រងបាន។

គាត់ថា ចំណុចសំខាន់ៗទាំងបួននេះ គឺជាការពឹងផ្អែកលើព្រះ។ ប៉ុន្តែ យើងត្រូវតែយកចំណុចទាំងបួននេះមកអនុវត្ត ឲ្យបានច្បាស់លាស់ គឺមិនគ្រាន់តែដឹងប៉ុណ្ណោះឡើយ។ ការដែលយើងស្ថិតនៅក្នុងស្ថានភាពដែលធ្វើ

ឲ្យយើងទន់ខ្សោយ និងបាត់បង់សមត្ថភាព និងកម្លាំង គឺជាព្រះពរមួយ ព្រោះវាជួយយើង ឲ្យចូលទៅចំពោះព្រះជាម្ចាស់ ហើយសូមឲ្យទ្រង់ជួយយើង។

គាត់មានប្រសាសន៍ទៀតថា ពេលដែលគាត់ចាប់ផ្តើមបញ្ចូលការលត់ដំទាំងនេះ ក្នុងជីវិតរបស់គាត់ គាត់ក៏បានស្គាល់ព្រះយេស៊ូវ កាន់តែច្បាស់ជាងមុន។ ពេលនោះ ព្រះអង្គបានបង្ហាញឲ្យគាត់ដឹងថា ព្រះអង្គមានភាពគ្រប់គ្រាន់សម្រាប់គាត់ នៅក្នុងបញ្ហាប្រចាំថ្ងៃ ដែលគាត់បានព្រួយបារម្ភនោះ។ ហើយខណៈពេលដែលទ្រង់បន្តជួយគាត់ ក្នុងពេលដ៏ពិបាក គាត់ក៏បានចាប់ផ្តើមទុកចិត្តទ្រង់កាន់តែខ្លាំងឡើង ហើយគាត់ក៏មានទំនុកចិត្តកាន់តែច្រើនផងដែរ។

ការលត់ដំទាំងបួន ដែលមានការអានព្រះបន្ទូល ការអធិស្ឋាន ការទុកចិត្ត និងការស្តាប់បង្គាប់ បានបង្រៀនគាត់ថា អ្វីដែលគាត់ត្រូវធ្វើ ពេលដែលគាត់មានការព្រួយបារម្ភ គឺត្រូវថ្វាយការព្រួយបារម្ភនោះដល់ព្រះជាម្ចាស់។ ពេលដែលគាត់បានថ្វាយការព្រួយបារម្ភដល់ព្រះអង្គ គឺមានន័យថា គាត់បានអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការទ្រង់ ក្នុងជីវិតគាត់។ ដូចនេះ គាត់មានហេតុផលកាន់តែតិច ដែលត្រូវព្រួយបារម្ភ។

គាត់ថា យើងប្រហែលជាព្យាយាមបង្ហាញឲ្យគេមើលឃើញថា យើងខ្លាំង និងរឹងមាំ ហើយស្ងើចសរសើរយើង នៅពេលយើងមានទុក្ខលំបាក ហើយយើងប្រហែលជាគិតថា ការព្យាយាមធ្វើដូចនេះ គឺជាការបម្រើដល់ព្រះ ប៉ុន្តែ ការគិតដូចនេះ គឺមិនត្រឹមត្រូវទេ ព្រោះវាអាចធ្វើឲ្យពួកគេមើលរំលងជំនួយរបស់ព្រះជាម្ចាស់ ដែលទ្រង់សព្វព្រះទ័យឲ្យពួកគេសង្ឃឹម និងទទួល។ ព្រោះការនេះនឹងលើកទឹកចិត្តពួកគេឲ្យពឹងផ្អែកខ្លួនឯង ជាជាងពឹងផ្អែកលើជំនួយរបស់ព្រះអង្គ។ ប៉ុន្តែ បើសិនជាពួកគេបានឃើញអ្នកទន់

ខ្សោយ ដែលបានរៀនឲ្យមានភាពរឹងមាំ ដោយបន្តទទួលកម្លាំងពីព្រះជាម្ចាស់ ពួកគេនឹងមានពេញដោយក្តីសង្ឃឹម។ គឺសង្ឃឹមថា ទ្រង់ក៏នឹងជួយពួកគេផងដែរ។

បើអ្នកកំពុងតែតយុទ្ធនឹងការព្រួយបារម្ភ ឬការថប់បារម្ភ សូមទៅប្រាប់អ្នកដឹកនាំពួកជំនុំ ឬគ្រីស្ទបរិស័ទណាម្នាក់ ដែលអ្នកស្គាល់ ដើម្បីឲ្យពួកគេអាចអធិស្ឋានជាមួយអ្នក។ ពួកគេនឹងអាចជួយអ្នក ឲ្យកែប្រែការព្រួយបារម្ភ ឲ្យក្លាយជាឱកាសចូលទៅជិតព្រះជាម្ចាស់ ដោយពឹងផ្អែកលើទ្រង់ ជាជាងបែរចេញពីព្រះអង្គកាន់តែឆ្ងាយ។

---

*យើងក៏ត្រូវទុកចិត្តព្រះចំពោះការអ្វីដែលយើងមិនអាចគ្រប់គ្រងបាន។ ហើយយើងស្តាប់បង្គាប់ទ្រង់ក្នុងរឿងអ្វីដែលយើងអាចគ្រប់គ្រងបាន។*

---